NUON CHEA DEFENCE TEAM
EXTRAORDINARY CHAMBERS IN THE COURTS OF CAMBODIA

ភ្នំពេញថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១

ចៅក្រម យូ ប៊ុនឡេង
ការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

តាមរយៈ សារអេឡិចត្រូនិច

**កម្មវត្ថុ: សំណើសុំបញ្ជីសម្ភារៈដែលជិតជាមក្នុងសំណុំរឿង ០០២ និង ស្នើឲ្យឈប់ពីការខារ**

លោកចៅក្រម យូ ប៊ុនឡេង ជាទីគោរព:

យើងបានអានដោយស្រងាកចិត្តនូវសេចក្តីសម្រេចនាពេលថ្មីៗនេះរបស់អង្គបុរេជំនុំជម្រះលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ Robert Hamill នៅក្នុងសំណុំរឿង ០០៣ នៅ អវតក[1] និងរបាយការណ៍សារព័ត៌មានជាបន្តបន្ទាប់[2]។

បន្ទាប់ពីបានអានយោបល់ដាច់ដោយឡែករបស់ចៅក្រម Downing និងចៅក្រម Lahuis[3] យើងយល់ឃើញថា លោកចៅក្រម (និងសហសេវិករបស់លោកដែលទើបតែចាកចេញ) បាន "ប្រព្រឹត្តភាពមិនប្រក្រតីធ្ងន់ធ្ងរខាងនីតិវិធី រួមមានការចុះកាលបរិច្ឆេទថយក្រោយលើឯកសារ ការ

---

[1] ឯកសារលេខ D-11/2/4/4, "សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលអ្នកដាក់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី Rober Hamill ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ERN 00748542–00748564 ("សេចក្តីពិចារណារបស់ អបជ")។

[2] សូមមើលផងដែរ Julia Wallace, *Cambodia Daily*, 'KRT Judges List Failings of Blunk, Bunleng', ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១១); Mary Kozlovski, *Phnom Penh Post*, 'Judges Decry KRT Missteps', ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១១) ។

[3] សូមមើលការពិចារណារបស់ អបជ នៅកថាខណ្ឌទី១២-១៦ (ទំព័រ ៩-១២) ។

កែប្រែជាសម្ងាត់នូវឯកសារ និងការខកខានមិនបានជូនដំណឹងឲ្យបានត្រឹមត្រូវដល់មេធាវីការពារក្តី” ក្នុងសំណុំរឿង ០០៣[4]។

ដោយពិចារណាលើតួនាទីដ៏សំខាន់របស់លោកចៅក្រមក្នុងការស៊ើបអង្កេត និងតាក់តែងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ ការលាតត្រដាងថ្មីៗនេះរបស់ចៅក្រមបរទេសនៅអង្គបុរេជំនុំជម្រះ បង្ហាញពីមន្ទិលសង្ស័យលើសុច្ចរិតភាពក្នុងសំណុំរឿង ០០២ និងដីកាដំណោះស្រាយ។ អាស្រ័យហេតុនេះហើយ យើងខ្ញុំសូមស្នើលោកចៅក្រមបង្ហាញជាបន្ទាន់នូវរាល់ឯកសារក្នុងសំណុំរឿង ០០២ ដែលមានការចុះកាលបរិច្ឆេទថយក្រោយ កែប្រែជាសម្ងាត់លើឯកសារ ឬក៏កែក្លែង, និង/ឬ លាក់បំបាត់ពីមេធាវីការពារក្តី។

យើងខ្ញុំចាត់ទុកសេក្តីថ្លែងការរបស់ចៅក្រមបរទេសនៃ អបជ បង្កើតបានជាអ្វីដែលលើសពី “ភស្តុតាងបឋម (*Prima facie*) នៃការប្រព្រឹត្តមិនត្រឹមត្រូវយ៉ាងធ្ងន់ធ្ងរ”[5]។ សេចក្តីថ្លែងការនេះនាំទៅរកការសន្និដ្ឋានដែលស្ទើរតែមិនអាចចៀសមិនផុតថា លោកចៅក្រម និងចៅក្រម Blunk បានចូលរួមក្នុងការប្រព្រឹត្តមួយដែលអាចពិពណ៌នាបានថាជាបទឧក្រិដ្ឋ[6]។

នៅក្នុងចម្លើយតបដែលចេញដោយការិយាល័យរបស់លោកកាលពីម្សិលមិញ លោកបានលើកឡើងថា “ការកែតម្រូវតែលើចំនុចភ័ន្តច្រឡំខ្លះតែប៉ុណ្ណោះ”[7] គឺមិនត្រឹមត្រូវទេ ដោយសារតែវាមិនបានបង្ហាញពីអ្វីដែលយើងខ្ញុំចាត់ទុកថា ជាការប្រព្រឹត្តខុសដ៏ធ្ងន់ធ្ងររបស់លោក គឺការកែបន្លំការរកឃើញក្រោយអង្គហេតុរបស់តុលាការ (*post facto*) ដែលអាចប្តឹងឧទ្ធរណ៍បាន ។ ដូចដែលបាន

---

[4] Julia Wallace, *Cambodia Daily*, ‘KRT Judges List Failings of Blunk, Bunleng’, ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១១ ។

[5] Mary Kozlovski, *Phnom Penh Post*, ‘Judges Decry KRT Missteps’, ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០១១ ។

[6] សូមមើល ឧបទាហរណ៍មាត្រា ៦២៩ នៃក្រមព្រហ្មទណ្ឌ (ការក្លែងបន្លំប្រព្រឹត្តនៅក្នុងលិខិតយថាភូត ឬការក្លែងបន្លំប្រព្រឹត្តនៅក្នុងឯកសារដែលចេញដោយរាជការសាធារណៈ ដើម្បីធ្វើការកត់សំគាល់សិទ្ធិ អត្តសញ្ញាណព ឬឋានៈ ដើម្បីយល់ព្រមដល់ការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ ឆ្នាំ ទៅ១០ ឆ្នាំ )។

[7] សូមមើលសេចក្តីថ្លែងការណ៍ពីការិយាល័យសហចៅក្រមស៊ើបអង្កេត (អត្ថបទបកប្រែក្រៅផ្លូវការ) ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ ។

កត់សម្គាល់ដោយចៅក្រម Downing និងចៅក្រម Lahuis "ការកែបន្ថែទាំងនេះមានគោលបំណង ដោយមិនសមហេតុផល ដើម្បីជួសជុលការខូចខាតនានានៅក្នុងដីកាដែលត្រូវបានជំទាស់"[8] ។

ហេតុដូច្នេះ យើងខ្ញុំបញ្ជូនលិខិតនេះទៅព្រមជាមួយសំណើសុំឱ្យមានការស៊ើបអង្កេតខាងវិន័យចំពោះការប្រព្រឹត្តខុសរបស់លោកចៅក្រម ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[9] ។

ដោយគោរព

Michiel PESTMAN & Victor KOPPE
សហមេធាវីបរទេស

Andrew IANUZZI & Jasper PAUW
ទីប្រឹក្សាច្បាប់

ចម្លងជូនៈ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍
ប្រធានគណៈមេធាវីកម្ពុជា
អគ្គលេខាធិការរងអង្គការសហប្រជាជាតិ
អវតក អង្គជំនុំជម្រះសាលាដំបូង
អវតក ចៅក្រម អបជ
អវតក ការិយាល័យរដ្ឋបាល
អវតក ការិយាល័យសហព្រះរាជអាជ្ញា
អវតក មេធាវីការពារក្តី និង អង្គភាពគាំពារការការពារក្តី
អវតក មេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

---

[8] សូមមើលការពិចារណារបស់ អបជ នៅកថាខណ្ឌទី១៤ (ទំព័រ ១០) (បញ្ជាក់បន្ថែម) ។

[9] សូមមើលរដ្ឋធម្មនុញ្ញកម្ពុជានៅមាត្រា ១៣២ (ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។ មាត្រា ១៣៣៖ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស។ មាត្រា១៣៤៖ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូលឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យលើករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា) សូមមើលផងដែរច្បាប់ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅមាត្រា ៩, ១២- ១៧ ។